## ២.២ ការពង្រីកការអប់រំកុមារតូច

### វត្ថុបំណង និងយុត្តិកម្ម

ផលសម្រេចនៃកម្មវិធីអប់រំកុមារតូច (ECE) គឺពង្រីកការចូលរៀនដោយសមធម៌សម្រាប់កុមារអាយុ ៥ ឆ្នាំ ដោយផ្តោតទៅលើឃុំ-សង្កាត់ដែលមានអត្រាចូលរៀនទាប និងអត្រាត្រួតថ្នាក់ខ្ពស់នៅបឋមសិក្សា ។ ទិសដៅជាយុទ្ធសាស្ត្ររួមគឺ ការអនុវត្តគោលវិធីផ្អែកលើសហគមន៍ និងសិស្សមជ្ឈមណ្ឌល ដែលនឹងអាចពង្រីកការគ្របដណ្តប់ និងភាពអាចទ្រទ្រង់បាន បានល្អប្រសើរជាងប្រព័ន្ធមត្តេយ្យសាលាបច្ចុប្បន្ននេះ ។ កម្មវិធីនេះនឹងជួយបំពេញបន្ថែមដោយកម្មវិធីសាកល្បង ដែលផ្តល់ថវិកាដោយអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយនានា រួមទាំងការអប់រំកុមារតូចដែលគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងគោលវិធីអប់រំផ្អែកលើខ្នងផ្ទះ ។ នាយកដ្ឋានអប់រំកុមារតូច ទទួលខុសត្រូវចំពោះការត្រួតពិនិត្យជាយុទ្ធសាស្ត្រ និងការធានាគុណភាព ។

ការពង្រីកការអប់រំកុមារតូច គឺជាយុទ្ធសាស្ត្រគន្លឹះមួយក្នុងការដោះស្រាយការចូលរៀនយឺតនៅសាលាបឋមសិក្សា កាត់បន្ថយការរៀនត្រួតថ្នាក់ទី ១-២ និងការបោះបង់ការសិក្សានៅថ្នាក់ទី ៤-៦ បង្កើនអត្រាបញ្ចប់ការសិក្សា និងកែលំអការសិក្សារបស់សិស្ស ។ ការផ្តល់ការអប់រំកុមារតូចចំពោះកុមារអាយុ ៥ ឆ្នាំ នឹងផ្តល់នូវការត្រៀមលក្ខណៈដ៏ល្អសម្រាប់សិស្សចូលរៀននៅបឋមសិក្សា និងជួយអោយកុមារបានចូលរៀននៅអាយុ ៦ ឆ្នាំ ។

### អាំងឌីកាទ័រ និងចំណុចដៅ

- បង្កើនការចូលរៀនរបស់កុមារតូចអាយុ ៥ ឆ្នាំ ទាំងក្នុងប្រព័ន្ធ និងផ្អែកលើសហគមន៍ ពី ២០% នៅឆ្នាំ ២០០៥ ទៅ ៥០% នៅឆ្នាំ ២០១០ ។
- បង្កើនការចូលរៀនរបស់កុមារតូចអាយុពី ៣-៥ ឆ្នាំ ទាំងក្នុង និងផ្អែកលើសហគមន៍ ពី ១០% នៅឆ្នាំ ២០០៥ ទៅ ៣០% នៅឆ្នាំ ២០១០ ។
- វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តកម្មវិធីអប់រំកុមារតូច ក្នុងអំឡុង ឆ្នាំ ២០០៥-២០០៦ ។

### យុទ្ធសាស្ត្រ និង វិសាលភាព

ទិសដៅអប់រំសម្រាប់ទាំងអស់គ្នា នឹងមិនអាចសម្រេចបានទេ បើគ្រាន់តែផ្តល់មត្តេយ្យសិក្សាក្នុងប្រព័ន្ធប៉ុណ្ណោះ ។ ដើម្បីជំនះបញ្ហានេះ នាយកដ្ឋានអប់រំកុមារតូចនឹងរៀបចំអាទិភាពជួយគាំទ្រដល់ការប្រមូលកម្មវិធីនានា តាមរយៈបង្កើនការផ្តោតការយកចិត្ត ដោយផ្តល់អន្តរាគមន៍ទៅតាមតម្រូវការ រួមមានគោលវិធីអប់រំផ្អែកលើសហគមន៍ និងតាមខ្នងផ្ទះ ការចូលរួមពីផ្នែកពាក់ព័ន្ធ និងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ពិសេសនៅតំបន់ជួបការលំបាក និងតំបន់ផ្តល់សេវាមិនបានគ្រប់គ្រាន់ ព្រមទាំងការលើកទឹកចិត្តអោយមានការទទួលខុសត្រូវអន្តរក្រសួងកាន់តែច្រើនថែមទៀត លើការផ្តល់សេវាអប់រំកុមារតូច ។

### កម្មវិធី និងសកម្មភាពចម្បង១

- ពង្រីក និងជំរុញការចូលរៀនចំពោះកុមារអាយុពី ៣ ទៅ ៥ ឆ្នាំ ពិសេសកុមារអាយុ ៥ ឆ្នាំ អោយមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលរៀនថ្នាក់ទី ១ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ។ ចំពោះកុមារអាយុក្រោម ៦ ឆ្នាំដែលពុំទាន់បានឆ្លងកាត់សាលាមត្តេយ្យ ត្រូវរៀបចំ និងសាកល្បងអនុវត្តកម្មវិធីរយៈពេល ២ ខែ មុនចូលរៀនថ្នាក់ទី ១ នៃសាលាបឋមសិក្សា ។ កម្មវិធីនេះ ផ្តោតទៅលើការបំប៉នគ្រូមត្តេយ្យលើវិធីសាស្ត្របង្រៀន និង រៀន ព្រមទាំងរៀបចំតែសស្តង់ដាការសិក្សាដោយនាយកដ្ឋានអប់រំកុមារតូច ។
- ពង្រីកកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ និងផ្អែកលើសហគមន៍ ដែលរួមមានយុទ្ធនាការផ្សព្វផ្សាយព័ត៌មានតាមសហគមន៍ ដើម្បីផ្តល់អន្តរាគមន៍ទាំងស្រុងដល់ការអប់រំកុមារតូច ជាពិសេសនៅក្នុងមជ្ឈដ្ឋានដែលមានការលំបាក តាមរយៈមាតាបិតា/អ្នកគាំពារកុមារ ដោយធ្វើសកម្មភាពនៅក្នុង និងជុំវិញសហគមន៍ និងតាមខ្នងផ្ទះ ។
- ពង្រឹងការពិនិត្យតាមដាន ដោយផ្តល់ថវិកាប្រតិបត្តិការសម្រាប់មន្ត្រីថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង ដើម្បីគាំទ្រដល់ការកសាងផែនការ ការគ្រប់គ្រង និង សកម្មភាពពិនិត្យតាមដាន ។

### ការគ្រប់គ្រង និង ការពិនិត្យតាមដាន

នាយកដ្ឋានអប់រំកុមារតូច ទទួលខុសត្រូវលើការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីនេះ ។ ក្រសួងអប់រំ យុវជន និង កីឡា នឹងពិនិត្យឡើងវិញការរៀបចំស្ថាប័នសមស្របដទៃទៀត រួមមានការទទួលខុសត្រូវរបស់ថ្នាក់ខេត្ត-ក្រុង និងស្រុក-ខណ្ឌ ព្រមទាំងការសម្របសម្រួលផងដែរជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត រួមមានគណៈកម្មាធិការ និងលេខាធិការដ្ឋានអប់រំសម្រាប់ទាំងអស់គ្នា និង ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

### ផែនការហិរញ្ញវត្ថុ

ដោយការផ្តល់សេវាគាំពារ និងអភិវឌ្ឍកុមារតូចរបស់រាជរដ្ឋាភិបាលនៅមានកំរិត ចាំបាច់ត្រូវមានការចូលរួមវិភាគទានពីភាគីមិនមែនរដ្ឋាភិបាល ដែលរួមមាន ការចូលរួមវិភាគទានសម្ភារៈ និងកំលាំងពលកម្មពីសហគមន៍ ការផ្តល់ហិរញ្ញប្បទានពីដៃគូផ្អែកឯកជន និង ការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយនានា ។

*តារាងទី២ : ផែនការហិរញ្ញវត្ថុសម្រាប់ការអប់រំកុមារតូច*

| សកម្មភាព | ចំណាយគិតជាលានរៀល | | | | |
|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 |
| ១- មត្តេយ្យសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ | 600 | 645 | 790 | 835 | 920 |
| ២- ការអប់រំកុមារតូចផ្អែកលើសហគមន៍ និងតាមខ្នងផ្ទះ | 100 | 135 | 145 | 200 | 210 |
| ៣- ពង្រឹងការគាំទ្រ និងការពិនិត្យតាមដានកម្មវិធី | 55 | 65 | 65 | 65 | 70 |
| **ធនធានសរុប** | **755** | **845** | **1,000** | **1,100** | **1,200** |

**តម្រូវការកសាងសមត្ថភាព :**

- បំប៉នសមត្ថភាពមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ លើការងាររដ្ឋបាល បច្ចេកទេស និង របៀបកែលំអទំនាក់ទំនង និង សហប្រតិបត្តិការ ពិសេសថ្នាក់ស្រុក-ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ និង អ្នកដឹកនាំក្រុមថែទាំកុមារតូចៗនៅតាមសហគមន៍ ឬម៉ែៗបង្គោល ។
- គាំទ្រមន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូច នៅរដ្ឋបាលកណ្តាល និង ខេត្ត-ក្រុង លើការបង្កើនគុណវុឌ្ឍិនៅក្នុងផ្នែកនេះ និង មុខវិជ្ជាដែលពាក់ព័ន្ធ ។